គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP- IDA
KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីថ្លែងការណ៍ ស្តីពីៈ

## គណៈកម្មាធិការប្រព្រឹត្តិកម្មអបអរសាទរទិវាពលកម្មអន្តរជាតិ ខួបលើកទី១២៤

នៅក្នុងឱកាស នៃ ការប្រារព្ធទិវាពលកម្មអន្តរជាតិខួបលើកទី១២៤ ថ្ងៃទី១ ឧសភា ឆ្នាំ២០១០ នេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដែលជាសម្ព័ន្ធ នៃ សមាគម-អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសមាជិកចំនួន២៣ សូមសំដែងក្តីសោមនស្ស និងចូលរួមអបអរសាទរយ៉ាងកក់ក្តៅចំពោះការប្រារព្ធទិវានេះ នៅទូទាំងពិភពលោក និងជាពិសេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមអង្គការសង្គមស៊ីវិល និង ក្រុមសហព័ន្ធសហជីពផ្សេងៗ ។

ទិវាពលកម្មអន្តរជាតិ ឬទិវានៃសេចក្តីប្រកាសអន្តរជាតិអំពីសិទ្ធិការងារ គឺជាទិវាដ៏មានសារៈសំខាន់ដែលបានឆ្លុះបញ្ចាំងនូវកិច្ចខិតខំប្រឹងប្រែង និងពលិកម្មទាំងឡាយរបស់វីរៈកម្មករ-ពលករ ដែលបានពុះពារក្នុងការទាមទារឱ្យមានការគោរពនូវសិទ្ធិ និងសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស ។ ជាងនេះទៀត ទិវាពលកម្មអន្តរជាតិ ដែលបានកំពុងប្រារព្ធធ្វើឡើងនេះ កាន់តែជំរុញឱ្យមានការខិតខំជាបន្តបន្ទាប់ថែមទៀតក្នុងគោលដៅជំរុញឱ្យមានការគោរពសិទ្ធិការងារ ព្រមទាំងលើកស្ទួយនូវលក្ខខណ្ឌការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែប្រសើរឡើង ។

ឆ្លៀតក្នុងឱកាសដ៏មានអត្ថន័យជាប្រវត្តិសាស្ត្រនេះ ក្នុងនាមអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការលើកស្ទួយការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ គណៈកម្មាធិការប្រព្រឹត្តិកម្មសូមចូលរួមអបអរនិងគាំទ្រចំពោះការប្រារព្ធទិវានេះ និងគោលជំហរសំដែងឡើងដោយក្រុមសហព័ន្ធសហជីព ដូចជា ការទាមទារឱ្យគោរពលក្ខខណ្ឌការងារមួយចំនួន និងការសុំតំលើងប្រាក់បៀវត្សរបស់គេរហូតដល់ ៩៣ដុល្លារ ក្នុង១ខែ ដើម្បីអាចឱ្យរស់នៅបានសមរម្យ ។ ប៉ុន្តែទន្ទឹមនឹងនេះដែរ យើងខ្ញុំក៏សូមសំដែងនូវក្តីព្រួយបារម្ភអំពីការគោរព ក៏ដូចជាការអនុវត្តន៍សិទ្ធិការងារកន្លងមកនេះ ដែលត្រូវបានរំខាន ឬរំលោភបំពានដោយអាជ្ញាធររាជរដ្ឋាភិបាលកម្ពុជា ឧទាហរណ៏ដូចជាៈ ការសំដែងមតិ និងការជួបប្រជុំដោយសន្តិវិធី, ការធ្វើកូដកម្ម និង សេរីភាពក្នុងការបង្កើតសហជីព ជាដើម ។

ដូចនេះ យើងខ្ញុំ សូមសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធដទៃទៀត បន្តចូលរួមលើកតំកើងនូវការគោរព និងការអនុវត្តន៍សិទ្ធិការងារឱ្យបានកាន់តែល្អ និងមានប្រសិទ្ធិភាព ដូចដែលបានចែងទទួលស្គាល់នៅក្នុងសេចក្តីប្រកាសអន្តរជាតិស្តីពីសិទ្ធិការងារ និងច្បាប់ការងាររបស់កម្ពុជា ជាពិសេសការអនុវត្តន៍នូវសិទ្ធិសេរីភាព របស់កម្មករនិយោជិតក្នុងការសំដែងមតិទាមទារនូវការអនុវត្តន៍លក្ខខណ្ឌការងាររបស់គេ ជាពិសេសពង្រឹងយន្តការដោះស្រាយវិវាទការងារប្រកបដោយសន្តិវិធី និងយុត្តិធម៌ ។

*ភ្នំពេញ ថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១០*

☏ ***សំរាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ***

| | | |
|---|---|---|
| លោក ហង្ស ឆាយា | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខៈ ០១២ ៨៦៥ ៩១០ |
| លោក ធន សារាយ | ប្រធានសមាគមអាដហុក | ទូរស័ព្ទលេខៈ ០១៦ ៨៨០ ៥០៩ |
| លោក សុក សំអឿន | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខៈ ០១២ ៩០១ ១៩៩ |
| លោកស្រី ស៊ុន ចាន់សែន | ប្រធានសមាគម KYA | ទូរស័ព្ទលេខៈ ០១៧ ៧៨៨ ៩៥៥ |
| លោកស្រី សយ សារាវឌ្ឍនី | នាយិកាប្រតិបត្តិអង្គការ CWCC | ទូរស័ព្ទលេខៈ ០៩២ ៩៩៣ ៣៩៨ |